ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
នាយកដ្ឋានសវនកម្មផ្ទៃក្នុង
លេខ......១៤៩......ន-សផក

ថ្ងៃ...........ខែ...........ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០២៤

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**កម្មវត្ថុ:** របាយការណ៍កែលម្អតាមអនុសាសន៍បានផ្តល់ឱ្យសម្រាប់ការិយបរិច្ឆេទ២០២២ នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះវិហារ

**យោង:** -ផែនការសវនកម្មផ្ទៃក្នុងនិងផែនការតាមដានអនុសាសន៍ប្រចាំឆ្នាំ២០២៤ លេខ១២០ ដនស/នា.សផក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-លិខិតបញ្ជាបេសកកម្មលេខ១៣៧,១៣៩ ដនស ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពអនុញ្ញាតជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ប្រតិភូសវនករបានចុះពិនិត្យការកែលម្អតាមអនុសាសន៍សវនកម្មផ្ទៃក្នុង នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី**ខេត្តព្រះវិហារ** ដែលប្រតិភូសវនករផ្តល់ឱ្យសម្រាប់ការិយបរិច្ឆេទឆ្នាំ២០២២ វិធានការកែលម្អរបស់ អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចុះអធិការកិច្ចសម្រាប់ការិយបរិច្ឆេទ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធបានផ្តល់អនុសាសន៍ ដូចខាងក្រោម÷

**ក.អនុសាសន៍របស់សវនកម្មផ្ទៃក្នុង÷**

១.មន្ទីរត្រូវខិតខំជំរុញបន្ថែមទៀត និងពន្យល់ណែនាំឱ្យម្ចាស់សំណង់មកស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានមុនធ្វើការសាងសង់ និងលិខិតបិទការដ្ឋាននៅពេលសំណង់សាងសង់ហើយ។

២.មន្ទីរត្រូវរៀបចំកន្លែងបំពាក់ប្រព័ន្ធការពារអគ្គីភ័យនៅក្នុងបន្ទប់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS) ដែលមានដាក់ម៉ាស៊ីនមេ(server) និងឃ្លាំងទុកដាក់ឯកសារសុរិយោដី និងភូមិសាស្ត្រឱ្យបានឆាប់រហ័ស។

**ខ.វិធានការកែលម្អរបស់អគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷**

១-រាល់វិក្កយបត្រទូទាត់ចំណាយរជ្ជទេយ្យបុរេប្រទាន ត្រូវចុះលេខ និងមានប្រភពច្បាស់លាស់ស្របតាមប្រកាសលេខ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

២-រាល់ការចុះបំពេញបេសកកម្ម ត្រូវមានរបាយការណ៍លទ្ធផលបេសកកម្មភ្ជាប់ឱ្យបានត្រឹមត្រូវស្របតាមប្រកាសលេខ០៩៩ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយប្រាក់បេសកកម្មក្នុង និងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ជាតិ។

៣-រាល់កិច្ចសន្យាកិច្ចលទ្ធកម្ម ត្រូវមានហត្ថលេខាខ្លីពីគ្រប់ភាគីពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់ ស្របតាមសារាចរណែនាំលេខ០០២ សហវ.អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

៤-ការប្រើប្រាស់ប្រេងឥន្ធនៈ សម្ភារការិយាល័យ ត្រូវមានបញ្ជីតាមដានសន្និធិឱ្យត្រឹមត្រូវស្របតាមវិធីគ្រប់គ្រងសន្និធិឃ្លាំង។

**គ. ផែនការការកែលម្អរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖**

១. ឧបសម្ព័ន្ធភ្ជាប់កិច្ចសន្យា និងបញ្ជីប៉ាន់តម្លៃសម្ភារមិនបានបញ្ជាក់ប្រភព។

២. អ្នកម្ចាស់ការមិនបានចេញលិខិតបញ្ជាក់ការបញ្ចប់ការងារសំណង់។

ឆ្លងតាមការពិនិត្យតាមអនុសាសន៍បានផ្តល់ឱ្យខាងលើនិងការបំភ្លឺបង្ហាញថា អង្គភាពរងសវនកម្មបានយកចិត្តទុកដាក់ក្នុងការកែលម្អនិងបានលទ្ធផលដូចខាងក្រោម៖

**ក. ការឆ្លើយតបចំពោះអនុសាសន៍សវនកម្មផ្ទៃក្នុង៖**

១. មន្ទីរបានឱ្យម្ចាស់សំណង់មកស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋាននៅក្នុងឆ្នាំ២០២៣ បានល្អប្រសើរដោយក្នុងរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ មានលិខិតអនុញ្ញាតសាងសង់ចំនួន១២ គម្រោង ហើយលិខិតបើកការដ្ឋានមានចំនួន០៩ គម្រោង ចំពោះលិខិតអនុញ្ញាតបិទការដ្ឋានសាងសង់មន្ទីរនឹងឱ្យម្ចាស់សំណង់មកស្នើសុំលិខិតបិទការដ្ឋាន(វិញ្ញាបនបត្រប្រើប្រាស់សំណង់)នៅពេលបញ្ចប់ការសាងសង់។

២. មន្ទីរបាននឹងកំពុងជួសជុលពង្រីក បន្ទប់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS) ដែលមានដាក់ម៉ាស៊ីនមេ (server) និងឃ្លាំងទុកដាក់ឯកសារសុរិយោដីនិងភូមិសាស្ត្រ ក្រោយបញ្ចប់ការជួសជុលមន្ទីរនឹងរៀបចំកន្លែងបំពាក់ប្រព័ន្ធការពារអគ្គិភ័យ។

**ខ. ការឆ្លើយតបចំពោះវិធានការកែលម្អរបស់អគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖**

១-មន្ទីរនឹងអនុវត្តវិក្កយបត្រទូទាត់ចំណាយរជ្ជទេយ្យបុរេប្រទាន ឱ្យស្របតាមប្រកាសលេខ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ចំពោះបច្ចុប្បន្នមន្ទីរអនុវត្តពុំទាន់បានដោយសារការទិញសម្ភារតាមរជ្ជទេយ្យពីកន្លែងទិញទំនិញក្នុងខេត្ត វិក្កយបត្រពុំមានចុះលេខ និងអាសយដ្ឋានច្បាស់លាស់នៅឡើយ។

២-មន្ទីរនឹងតម្រូវឱ្យមានរបាយការណ៍លទ្ធផលការងារចុះបេសកកម្មឱ្យស្របតាមប្រកាសលេខ០៩៩ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ស្តីពីរិធាន និងនីតិវិធីចំណាយប្រាក់បេសកកម្មក្នុង និងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ជាតិ ឱ្យបានគ្រប់ចំនួន។

៣-រាល់កិច្ចសន្យាកិច្ចលទ្ធកម្ម មន្ទីរបានចុះហត្ថលេខាខ្ទីពីគ្រប់ភាគីពាក់ព័ន្ធរួចហើយ។

៤-ការប្រើប្រាស់ប្រេងឥន្ធនៈ សម្ភារការិយាល័យ មន្ទីរនឹងរៀបចំធ្វើបញ្ជីតាមដានសន្និធិឱ្យស្របតាមវិធីគ្រប់គ្រងសន្និធិឃ្លាំង។

**គ. ការឆ្លើយតបចំពោះវិធានការកែលម្អរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួង ស.ហ.វ÷**

១. មន្ទីរបានធ្វើឧបសម្ព័ន្ធភ្ជាប់កិច្ចសន្យា និងបញ្ជីប៉ាន់តម្លៃសម្ភារដោយបានបញ្ជាក់ប្រភពរួចហើយ។

២. ក្នុងឆ្នាំ២០២៣មន្ទីរបានចេញវិញ្ញាបនបត្របញ្ចប់ការងារសំណង់តាមលិខិតលេខ០៣៤ ដនសស/ពហ/កល ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៣។

ទន្ទឹមនឹងនោះក៏នៅមានចំណុចសេសសល់ និងខ្វះខាតបន្តិចបន្តួចដែលមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះវិហារ នឹងធ្វើការកែលម្អបន្ថែមទៀត ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាប និងមានមតិដឹកនាំដ៏ខ្ពង់ខ្ពស់ ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ ។

**ប្រធាននាយកដ្ឋាន**

**យួន_សុជាតិ**

**មតិឯកឧត្តមរដ្ឋលេខាធិការប្រចាំការ**

**មតិឯកឧត្តមប្រធានក្រុមការងារ**

11/9

**មតិសម្រេចឯកឧត្តមឧបនាយករដ្ឋមន្ត្រី**